**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

លេខ....១១០.....ន-សផក

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខុទ្ទកាល័យ
ចូល លេខ 3168 ថ្ងៃទី 08.07.24

4133
10.7.24

ថ្ងៃ............ខែ........ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០២៤

**<u>សូមគោរពជូន</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ:</u>** របាយការណ៍កែលម្អតាមអនុសាសន៍បានផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទ២០២២ នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

**<u>យោង:</u>** -ផែនការសវនកម្មផ្ទៃក្នុងនិងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤ លេខ១១២០ ដនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-លិខិតបញ្ជាបេសកកម្មលេខ១១៧៤,១១៧៧ ដនស ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពអនុញ្ញាតជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ប្រតិភូសវនករបានចុះពិនិត្យការកែលម្អតាមអនុសាសន៍សវនកម្មផ្ទៃក្នុង នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**ខេត្តកំពត** ដែលប្រតិភូសវនករផ្តល់ឱ្យសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២២ វិធានការកែលម្អរបស់អគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចុះអធិការកិច្ចសម្រាប់ការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធបានផ្តល់អនុសាសន៍ដូចខាងក្រោម÷

**ក.អនុសាសន៍របស់សវនកម្មផ្ទៃក្នុង÷**

១. មន្ទីរត្រូវពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិត នៅក្នុងសៀវភៅចុះលេខលិខិតចេញឱ្យបានត្រឹមត្រូវ និងច្បាស់លាស់។

២. មន្ទីរត្រូវរំលេចនូវទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន-បិទការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរ។

៣. មន្ទីរត្រូវរៀបចំផ្លូវជុលពិតានដែលជ្រាបទឹកឱ្យបានស្អាតបាត និងបំពាក់ប្រព័ន្ធការពារអគ្គីភ័យឱ្យបានត្រឹមត្រូវ។

ខ.វិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷

១-មន្ទីរត្រូវជំរុញឱ្យមានការចុះហត្ថលេខាគ្រប់សមាសភាពអាជ្ញាធរគ្រប់គ្រង និងគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ លើកំណត់ហេតុស្តីពីការប្រជុំពិនិត្យ ផ្ទៀងផ្ទាត់ការរៀបចំតារាងកើនឡើងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២២ ឱ្យរួចរាល់ជាផ្លូវការ។

២-ឆ្នាំឃ្លាំងត្រូវធ្វើបញ្ជីវិភាគសម្រាប់កត់ត្រាតាមដានសន្និធិឃ្លាំង លើការប្រើប្រាស់សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល និងប្រេងឥន្ធនៈឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ស្របតាមនីតិវិធីនៃការគ្រប់គ្រងសន្និធិឃ្លាំង។

៣-លើឯកសារប្រើប្រាស់ប្រេងសម្រាប់ចុះបំពេញបេសកកម្មតាមបណ្តាក្រុង-ស្រុក មន្ទីរត្រូវមានភ្ជាប់លិខិតបេសកកម្មមកជាមួយឱ្យបានគ្រប់គ្រាន់។

ឆ្លងតាមការពិនិត្យតាមអនុសាសន៍បានផ្តល់ឱ្យខាងលើនិងការបំភ្លឺបង្ហាញថា អង្គភាពរងសវនកម្មបានយកចិត្តទុកដាក់ក្នុងការកែលម្អនិងបានលទ្ធផលដូចខាងក្រោម÷

**ក.ការឆ្លើយតបចំពោះអនុសាសន៍សវនកម្មផ្ទៃក្នុង÷**

១.មន្ទីរបានពង្រឹងការងាររដ្ឋបាលលើផ្នែកចុះលេខលិខិត នៅក្នុងសៀវភៅចុះលេខលិខិតចេញប្រចាំឆ្នាំ២០២៣ ល្អប្រសើរ។

២.មន្ទីរនឹងបញ្ចូលទិន្នន័យលិខិតអនុញ្ញាតបើកការដ្ឋាន និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងាររបស់មន្ទីរក្នុងពេលឆាប់ខាងមុខនេះ។

៣.មន្ទីរបាន និងកំពុងរៀបចំជួសជុលពិតានដែលជ្រាបទឹក ហើយនឹងបំពាក់ប្រព័ន្ធការពារអគ្គីភ័យក្នុងពេលឆាប់ៗ។

**ខ.ការឆ្លើយតបចំពោះវិធានការកែលម្អរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ÷**

១-មន្ទីរបានចុះហត្ថលេខាពីគ្រប់សមាសភាពអាជ្ញាធរគ្រប់គ្រង និងគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្នុងតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២២ រួចហើយ។

២-មន្ទីរបានធ្វើការកត់ត្រាតាមដានសន្និធិឃ្លាំងក្នុងការប្រើប្រាស់សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល និងប្រេងឥន្ធនៈ ស្របតាមនីតិវិធីនៃការគ្រប់គ្រងសន្និធិឃ្លាំង។

៣-មន្ទីរបានភ្ជាប់លិខិតបេសកកម្មជាមួយឯកសារប្រើប្រាស់ប្រេង សម្រាប់ចុះបំពេញបេសកកម្មតាមបណ្តាក្រុង-ស្រុក រួចរាល់។

ទន្ទឹមនឹងនោះក៏នៅមានចំណុចសេសសល់ និងខ្វះខាតបន្តិចបន្តួចដែលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត នឹងធ្វើការកែលម្អបន្ថែមទៀត ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

**ប្រធាននាយកដ្ឋាន**

យួន-សុជាតិ

| **មតិឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** | **មតិឯកឧត្តមប្រធានក្រុមការងារ** |
| --- | --- |
| | |

**មតិសម្រេចឯកឧត្តមឧបនាយករដ្ឋមន្ត្រី**